# លក្ខខណ្ឌយោង (ទីប្រឹក្សាក្នុងស្រុក)

**តួនាទី:** មន្ត្រីជំនាញផ្នែកតាមដាន និងវាយតម្លៃផ្នែករដ្ឋបាលចំណូលមិនមែនសារពើពន្ធ

**ទីកន្លែងបម្រើការងារ:** នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយ

## សាវតារ

អគ្គនាយកដ្ឋានគោលនយោបាយ ទទួលបន្ទុកលើការងារសម្របសម្រួល, ត្រួតពិនិត្យ និងវាយតម្លៃ (M&E) ការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩ - ២០២៣ និងការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ព្រមទាំងការស្រាវជ្រាវផ្សេងៗទាក់ទងនឹងគោលនយោបាយចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។

ដើម្បីធានាបាននូវប្រសិទ្ធភាពការងារពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល និងការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម អគ្គនាយកដ្ឋានមានតម្រូវការទីប្រឹក្សាក្នុងស្រុក ដែលមានឯកទេស ឬសមត្ថភាពពាក់ព័ន្ធនឹងការងារសម្របសម្រួល, តាមដាន និងវាយតម្លៃការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រ ក៏ដូចជា ជំនាញទាក់ទងនឹងរដ្ឋបាល និងគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការគ្រប់គ្រងក្របខ័ណ្ឌចំណូល និងចំណាយ។ សេវាកម្មរបស់ទីប្រឹក្សានេះ នឹងចូលរួមចំណែកក្នុងការសម្រេចបាននូវចង្កោមសកម្មភាព ដែលមានចែងក្នុងផែនការសកម្មភាពរួម របស់អគ្គនាយកដ្ឋានគោលនយោបាយ ។

ទីប្រឹក្សាក្នុងស្រុកជំនាញត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ផ្នែកចំណូលមិនមែនសារពើពន្ធត្រូវមានតួនាទី និងលក្ខណៈសម្បត្តិ ដូចខាងក្រោម÷

### ១. តួនាទី និងការទទួលខុសត្រូវ÷

- រៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ផ្នែកចំណូលមិនមែនសារពើពន្ធ,
- ធ្វើការសម្របសម្រួលរៀបចំផែនការ និងកសាងក្របខណ្ឌពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងវាយតម្លៃវិធានការផ្នែកចំណូលមិនមែនសារពើពន្ធក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣
- រៀបចំរបាយការណ៍វឌ្ឍនភាព និងការវាយតម្លៃទៅលើលទ្ធផលនៃការអនុវត្តវិធានការផ្នែកចំណូលមិនមែនសារពើពន្ធក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣
- តាមដាន និងវាយតម្លៃការកែទម្រង់រដ្ឋបាល និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ
- ធ្វើការស្ទង់មតិ, ប្រមូលទិន្នន័យ និងស្រាវជ្រាវផ្សេងៗដែលពាក់ព័ន្ធទៅនឹងចំណូលមិនមែនសារពើពន្ធ
- ធ្វើការវិភាគគោលនយោបាយផ្សេងៗក្រោមការណែនាំរបស់អគ្គនាយកដ្ឋានគោលនយោបាយ
- ចូលរួមវិភាគ និងព្យាករណ៍ចំណូល - ចំណាយសារធារណៈក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ។

### ២. លក្ខណៈសម្បត្តិ÷

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច, ការគ្រប់គ្រងអាជីវកម្ម, គោលនយោបាយសាធារណៈ ឬសញ្ញាបត្រដែលមានតម្លៃប្រហាក់ប្រហែល,

- មានបទពិសោធន៍ការងារយ៉ាងហោច ០២ឆ្នាំ ទាក់ទងនឹងការស្រាវជ្រាវ និងវាយតម្លៃ,
- មានបទពិសោធន៍ និងចំណេះដឹងទាក់ទងឧបករណ៍វាស់វែង(Tools), វិធិសាស្រ្ត(Methodologies), និងគោលការណ៍ (Principles) នៃការត្រួតពិនិត្យ និងវាយតម្លៃ (M&E),
- បង្ហាញសមត្ថភាពក្នុងការប្រមូល និងវិភាគទិន្នន័យ,
- មានជំនាញវិភាគគោលនយោបាយ និងដោះស្រាយបញ្ហាបានទាន់ពេលវេលា,
- មានលទ្ធភាពធ្វើការងារជាក្រុម និងនៅក្រោមសម្ពាធខ្ពស់,
- មានសមត្ថភាពល្អក្នុងការសរសេរ និងការនិយាយ ជាភាសាខ្មែរ និងអង់គ្លេស ។

ទីប្រឹក្សាក្នុងស្រុកនេះ នឹងស្ថិតនៅក្រោមការដឹកនាំរបស់ប្រធានក្រុមការងារនៃការិយាល័យវិភាគ និងព្យាករណ៍សារពើពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយ ព្រមទាំងអាចទទួលបានការបណ្តុះបណ្តាលបន្ថែមលើគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ និងការរៀបចំក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ។